# មាយាស្រី

## ភាគទី១

កាលពីព្រេងនាយ មានបុរសម្នាក់ មានប្រពន្ធនៅជាមួយគ្នា តែពុំមានកូនលុះយូរទៅប្រពន្ធនោះមានសាហាយ នាំមកដេកក្នុងផ្ទះសឹងតែរាល់ថ្ងៃ។ ថ្ងៃមួយប្ដីទៅដីកដំឡូងក្នុងព្រៃ ដល់ថ្ងៃក្ដៅចូលទៅអាស្រ័យនៅខ្ទមអ្នកតា១។ ប្រពន្ធរៀបអីវ៉ាន់ទៅបន់អ្នកតានោះឲ្យទៅធ្វើប្ដីឲ្យស្លាប់នឹងយកសាហាយធ្វើប្ដី រៀបស្រេចហើយ ក៏យកអីវ៉ាន់នោះដើរទៅក្នុងខ្ទមអ្នកតានោះ។ ប្ដីឃើញប្រពន្ធដើរចូលទៅខ្ទមអ្នកតា ក៏នឹកឆ្ងល់ថាប្រពន្ធអញ វាមករកអ្វីក្នុងខ្ទមអ្នកតានោះ? គិតហើយក៏ចូលទៅពួនក្រោយខ្នងអ្នកតា លបស្ដាប់ប្រពន្ធ។

ឯប្រពន្ធ ក៏ចូលទៅអុជទៀនធូប ហើយបន់អ្នកតាថា: "ខ្ញុំមិនចង់យកប្ដីខ្ញុំទេ ខ្ញុំយកប្ដីទៀតសូមអ្នកតាកាច់ប្ដីខ្ញុំឲ្យស្លាប់ទៅ ខ្ញុំនឹងថ្វាយជ្រូកមួយ"។ ប្ដីឮដូច្នោះក៏ឆ្លើយឡើងពីក្រោយខ្នងអ្នកតា "អើ បើនាងមានសាហាយហើយ បើចង់ឲ្យកាច់ប្ដីនាងឯងឲ្យស្លាប់នោះងាយទេ វិលទៅផ្ទះវិញត្រូវរកមាន់ក្រាបទាំងមេទាំងពងមួយសំបុក ស្ងោរឲ្យប្ដីនាងឯងស៊ីទៅ វាស្លាប់ហើយ"។

មេនោះឮដូច្នោះ ស្មានថាអ្នកតាបង្គាប់ ក៏ប្រញាប់វិលមកផ្ទះវិញរកទិញបានមេមាន់ក្រាបមួយសំបុក ស្ងោរទុកឲ្យប្ដីស៊ីដើម្បីនឹងឲ្យស្លាប់ ហើយនឹងបានយកសាហាយ។ លុះដល់ព្រលប់ ប្ដីមកពីដីកដំឡូង ដល់ផ្ទះហើយ សួរថា "គេហ៍អើយ! បានអីស៊ីបាយ?"។ មេនោះឆ្លើយថា "ខ្ញុំបានមេនិងពងមាន់ក្រាបមួយសំបុកស្ងោរទុកឲ្យអ្នក"។ ប្ដីថា "រៀបបាយមកស៊ី"។ ប្រពន្ធក៏លើកបាយព្រមទាំងមេ និងពងមានក្រាប មកឲ្យប្ដីស៊ី។ ប្ដីស៊ីអស់ហើយធ្វើជាឈឺដេកថ្ងូរហ៊ឺៗ។ មេនោះអរណាស់គិតស្មានថា ប្ដីឈឺមែន ត្រូវនឹងពាក្យអ្នកតាបង្គាប់ ហើយត្បិតឮថ្ងូរ។ ឯប្ដីក៏ធ្វើដេកទៅ។ មេនោះគិតស្មានថាប្ដីស្លាប់ ក៏បើកទ្វារនាំយកសាហាយចូលទៅដេកជាមួយ។ អ្នកទាំងពីរកំពុងតែនិយាយគ្នា ប្ដីក៏ក្រោកឡើងអង្គុយហៅប្រពន្ធមកប្រាប់ថា "រងាណាស់"។ ឯប្រុសសាហាយឃើញប្ដីមេនោះ ក្រោកឡើងអង្គុយដូច្នោះស្ទុះរត់ពុំទាន់ក៏ចូលទៅពួនក្នុងពាងធំ១ នៅខាងដំណេក សម្ងំចាំប្ដីនោះដេក ខ្លួននឹងចេញពីពាងទៅដេកនឹងមេនោះទៀត។

អត្ថបទដោយ៖ មាស សុភាព

ប្ដីបានឃើញ តែធ្វើមិនឃើញមិនដឹងប្រាប់ប្រពន្ធថា "រងាណាស់ ឯងដាំទឹកឲ្យក្ដៅផ្ទូតបន្តិច នឹងអាលស្ងាប់"។ មេនោះឮថាចង់ស្លាប់ដូច្នោះ អរណាស់ ស្មិតត្រូវនឹងពាក្យដែលត្រូវបន់អ្នកតា។ លុះប្រពន្ធដាំទឹកពុះហើយប្ដីថា "ទៅដងទឹកត្រជាក់បាន១ក្អមមកយកលាយទឹកក្ដៅនេះ"។ ប្រពន្ធឮប្ដីប្រើដូច្នោះ ក៏យកក្អមចេញទៅដងទឹក។ ប្ដីឃើញប្រពន្ធចេញទៅបាត់ក៏ក្រោកឡើង ដើរទៅលើកទឹកពុះ១ខ្ទះនោះ យកទៅស្រោចលើសាហាយដែលនៅក្នុងពាងនោះស្លាប់ទៅ ហើយចូលទៅដេកវិញធ្វើជាថ្ងូរហ៊ឺៗទៀត។

មេនោះវិលពីដងទឹកមកវិញ មើលទៅឃើញសាហាយត្រូវទឹកក្ដៅរួញសរសៃដូចគេដកចេញពីពាងមក ក៏ឱបខ្សឹបថា "ប្ដីក៏មិនឱនទៅវាមិនទាន់ទេ"។ អានោះធ្ងក់ដដែល។ មេនោះយកដៃទៅចាប់ជ្រមុជទៅ ត្រូវស្ទឹកត្រចៀករលេះជ្រុះទាំងសក់ មើលបានដឹងជាប្ដីស្រោចទឹកក្ដៅស្លាប់សាហាយទៅហើយ ក៏ពុំស្ដីយកគម្របពាងមកគ្រប ហើយយកទឹកទៅឲ្យប្ដីផ្ទូត។ ឯប្ដីក៏មិនស្ដី ទឹកក៏មិនផ្ទូត ប្រាប់ប្រពន្ធថា អញគ្រាន់បើហើយ។ ហើយហៅប្រពន្ធចូលទៅដេកទៅ។

លុះព្រឹកព្រហាមឡើង មេនោះពុំដឹងបើគិតដូចម្ដេច និងយកខ្មោចចេញផុតពីផ្ទះ ក៏នឹកឃើញថា "ក្នុងស្រុកនេះមានចោរ៤នាក់ តែងតែលបលួចអីវ៉ាន់អ្នកផងសព្វថ្ងៃ សព្វយប់គ្រប់ភូមិ ដូច្នេះអញនឹងគិតឲ្យចោរទាំង៤នាក់នោះ យកខ្មោចចេញពីផ្ទះអញទៅចោលក្នុងព្រៃឲ្យបាន" គិតហើយក៏ដើរខ្ចី សំពត់ ហូល អាវព្រែ គេយកមកហាលជុំវិញផ្ទះ។ ឯចោរទាំង៤នាក់នោះឃើញហើយគិតថា "ដើ! មេនោះមានណាស់តើ! យប់នេះយើងទៅលបលួចវាឲ្យបានកុំខាន សព្វថ្ងៃយើងស្មានថាវាក្រ"។ មេនោះក៏ហាលសំពត់អាវព្រៃនោះ លុះដល់ពេលល្ងាចយកទៅជូនគេវិញ ហើយយកខ្សែចងរឹតរួតពាងខ្មោចនោះឲ្យជាប់ ទុកឲ្យចោរលួចមកសែងយកទៅ។ ឯចោរទាំង៤នាក់ លុះយប់ក៏បបួលគ្នាទៅលួច ចូលទៅរករបស់ទាំងនោះពុំឃើញ ប្រទះឃើញតែពាងមួយ ចងមាត់ជាប់បើកពុំរួច។ ចោរទាំង៤នាក់និយាយគ្នាថា "របស់អស់នោះវាដាក់ក្នុងពាងនេះហើយ បើដូច្នេះត្រូវយើងសែងពាងនេះ" ថាហើយក៏នាំគ្នាសែងពាងនេះទៅ ដល់ព្រៃឆ្ងាយក៏ស្រាយលូកមើល។

***(សូមរង់ចាំតាមដានរឿងមាយាស្រី ភាគ២ ដែលជាភាគបញ្ចប់នៅសប្ដាហ៍ក្រោយ)***

អត្ថបទដោយ៖ មាស សុភាព